ធ៥-០៩-០១១ ប្រ.ក

# ប្រកាស
# ស្តីពី
# ការកំណត់អត្រាការប្រាក់លើប្រាក់បញ្ញើមានកាលកំណត់ ប្រាក់បញ្ញើទុនបម្រុងកាតព្វកិច្ច និងប្រាក់តម្កល់ធានាលើដើមទុនជារូបិយប័ណ្ណដុល្លារអាមេរិក

**ប្រការ ១**.-

អត្រាការប្រាក់លើប្រាក់បញ្ញើមានកាលកំណត់ ១ខែ ៣ខែ ៦ខែ ១ឆ្នាំ ដែលគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ដាក់ផ្ញើនៅធនាគារជាតិនៃកម្ពុជា ជាប្រាក់ដុល្លារអាមេរិក ត្រូវបានផ្តល់ជូនតាមអត្រា១/២ នៃ SIBOR (Singapore Inter-Bank Offered Rate)។

**ប្រការ ២**.-

អត្រាការប្រាក់លើប្រាក់បញ្ញើទុនបម្រុងកាតព្វកិច្ច (Reserve Requirement) ដែលត្រូវទទួលការប្រាក់ ត្រូវបានផ្តល់ជូនតាមមាត្រា ១/២ នៃSIBOR គិតលើមូលដ្ឋានមួយខែ។

**ប្រការ ៣**.-

អត្រាការប្រាក់លើប្រាក់តម្កល់ធានាលើដើមទុន (Capital Guarantee) ត្រូវបានផ្តល់ជូនតាមអត្រា ១/៤ នៃ SIBOR គិតលើមូលដ្ឋាន ៦ខែ។

**ប្រការ ៤**.-

លិខិតបទដ្ឋានទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៥**.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាព និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ នៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ៦**.-

ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ភ្នំពេញ, ថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៩

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ជា ចាន់តូ**